# សេចក្តីប្រកាសព័ត៌មាន
## ស្ថានទូតជប៉ុនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ ២០១៥

**ជំនួយរបស់ជប៉ុនសំរាប់**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)**

កាលពីថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១៥ រដ្ឋាភិបាលជប៉ុនបានបញ្ចេញប្រាក់ចំនួន **១.២២១.៨១៨ (មួយលានពីរសែនពីរម៉ឺនមួយពាន់ប្រាំបីរយដប់ប្រាំបី) ដុល្លាអាមេរិក** ជាវិភាគទានសំរាប់ឆ្នាំសារពើពន្ធ ២០១៥ របស់ខ្លួន ដើម្បីផ្តល់ជូនភាគីអង្គការសហប្រជាជាតិ នៃថវិកាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

រដ្ឋាភិបាលជប៉ុនបានសំរេចចិត្តផ្តល់វិភាគទាននេះ ដើម្បីបន្តទ្រទ្រង់ដំណើរការយុត្តិធម៌របស់សាលាក្តីខ្មែរក្រហម ក្នុងដំណាក់កាលដ៏សំខាន់នៅពេលដែល អ.វ.ត.ក បានជួបប្រទះនូវស្ថានភាពកង្វះខាតថវិកាដ៏ធ្ងន់ធ្ងរ ដោយកត់សំគាល់ផងដែរនូវភាពជឿនលឿនកាលពីពេលថ្មីៗនេះ ដូចជាសវនាការលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ដែលបានដំណើរការដោយអង្គជំនុំជម្រះតុលាការកំពូល និងការបន្តសវនាការលើភស្តុតាងពាក់ព័ន្ធនឹងបទចោទប្រកាន់នានារួមមានបទឧក្រិដ្ឋប្រល័យពូជសាសន៍ និងអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងសំណុំរឿង ០០២/០២ ។ ប្រទេសជប៉ុនចាត់ទុកថា វាមានសារៈសំខាន់សំរាប់ អ.វ.ត.ក ដើម្បីបន្តការកាត់ក្តីក្នុងរបៀបមួយមានភាពត្រឹមត្រូវ មានប្រសិទ្ធភាព និងឆាប់រហ័ស ដោយហេតុថា ជនជាប់ចោទមានវ័យកាន់តែចាស់ជរា និងសុខភាពទន់ខ្សោយ និងដើម្បីសំរេចបាននូវយុត្តិធម៌ដែលកំពុងត្រូវបានទន្ទឹងរង់ចាំអស់រយៈពេលយ៉ាងយូរមកហើយសំរាប់ប្រជាជនកម្ពុជា ។

រដ្ឋាភិបាលជប៉ុនផ្តល់សារៈសំខាន់ទៅលើសាលាក្តីខ្មែរក្រហម ដោយផ្អែកលើទស្សនៈចំនួនបី ។ ទីមួយ ការកាត់ក្តីខ្មែរក្រហមគឺជាដំណាក់កាលបញ្ចប់នៃដំណើរការស្វែងរកសន្តិភាពនៅកម្ពុជា ដើម្បីបង្ការទប់ស្កាត់ការកើតមានឡើងវិញនៃអំពើឃោរឃៅដែលបានប្រព្រឹត្តឡើងនៅក្នុងរបបខ្មែរក្រហម ។ ទីពីរ សាលាក្តីខ្មែរក្រហមនេះនឹងជួយស្វែងរកយុត្តិធម៌ជូនជនរងគ្រោះនៃរបបខ្មែរក្រហម ដែលប្រការនេះ នឹងរួមចំណែកដល់ការផ្សះផ្សាជាតិឡើងវិញ ។ ទីបី សាលាក្តីនេះនឹងរួមចំណែកដល់ការពង្រឹងនីតិរដ្ឋនៅកម្ពុជា ។

រដ្ឋាភិបាលជប៉ុនបាន និងកំពុងជួយដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា តាំងពីដើមដំបូងរៀងមកហើយគិតត្រឹមថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ ២០១៥ ជំនួយហិរញ្ញវត្ថុពីប្រទេសជប៉ុនសំរាប់តុលាការនេះ មានចំនួនប្រមាណជា ៨៣,៩៥ លានដុល្លាអាមេរិក ប្រហាក់ប្រហែលនឹង ៣៣% នៃវិភាគទានអន្តរជាតិសរុប ។ លើសពីនេះទៅទៀតប្រទេសជប៉ុនរួមជាមួយប្រទេសបារាំង ក្នុងឋានៈជាសហប្រធាននៃមិត្តរបស់ អ.វ.ត.ក. បានតាមដានដំណើរការរបស់តុលាការនេះយ៉ាងសកម្ម ។

---

សំរាប់ព័ត៌មានបន្ថែម សូមទាក់ទងលោក ហ្វូមីអូ ហ្គោតុ (ទូរស័ព្ទដៃលេខ ០១៦-៨៣៥ ៤០៦ អ៊ីមែល: fumio.goto@mofa.go.jp)
ស្ថានទូតជប៉ុន អាស័យដ្ឋានលេខ ១៩៤ មហាវិថីព្រះនរោត្តម ទូរសព្ទ: (០២៣) ២១៧ ១៦១/៤ ទូរសារ: ០២៣-២១៦ ១៦២
វេបសាយផ្លូវការ : www.kh.emb-japan.go.jp